ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
លេខៈ..១០៥..ក.ជ.ក.

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១៥

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ

## ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## សម្រេច

### ប្រការ១..

បង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងគោលបំណងពង្រឹងប្រព័ន្ធការពារកុមារ ដើម្បីបង្ការទប់ស្កាត់ ការពារ និងលុបបំបាត់រាល់ទម្រង់នៃការរំលោភបំពានផ្សេងៗនិងអំពើហិង្សាលើកុមារ សំដៅបម្រើឧត្តមប្រយោជន៍កុមារ។

### ប្រការ២..

គណៈកម្មការនេះ នឹងបំពេញមុខងារជាក្រុមការងារថ្នាក់ជាតិ ក្នុងការការពារកុមារពីការរំលោភបំពានគ្រប់រូបភាព។/

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារៈ ០២៣ ២១៣ ០០៤,០២៣ ២១៨ ០១៨
Cambodia National Council for Children. #788,Monivong Blvd, Phnom Penh,Cambodia. Fax/Phone: (855) 23 213 004,023 218 018